**ឯកសារស្រាវជ្រាវសង្ខេប**

ព្រឹទ្ធសភាភូមិភាគទី៥

# ការពង្រឹងការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន
# នៅខេត្ត កែប និងខេត្តកំពត


| | |
|---|---|
| អ្នកទទួលខុសត្រូវ៖ | កញ្ញា ជំពូនុត តាំងថារ៉ែន |
| ណែនាំដោយ ៖ | លោក សូ សុវណ្ណារិទ្ធ |
| អ្នកចូលរួម៖ | លោកស្រី គឹម កែវជីតា |
| | លោក ថេង ណាន |
| | លោក នន់ អស្សាច័ន្ទ |



ខែមេសា ឆ្នាំ២០១៦

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា វ).ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់ សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវ ទៅតាមសំណើរបសសមាជិក-សមាជិកា និងគណៈកម្ម-ការជំនាញរបស់រដ្ឋសភាព្រឹទ្ធសភា ដែលមានការវិភាគទៅលើ បញ្ហាដែល កំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗ ដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬ ភូមិភាគរបស់សមាជិក សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាងឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់ វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះ មានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃគេហទំព័រនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារនៅក្នុងគេហទំព័រនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៦ វិទ្យាស្ថានសភាកម្ពុជា ។(ក.ស.វ)

# មាតិកា


១. សេចក្តីផ្តើម ........ 1

២. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ........ 1

៣. ការវិភាជន៍ធនធាន ឃុំ សង្កាត់ ........ 2

៤. ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅខេត្តកំពត និងកែប ........ 3

៥.សេចក្តីសន្និដ្ឋាន ........ 9

ឧបសម្ព័ន្ធ ........ 10

ឯកសារយោង ........ 13

## ១. សេចក្តីផ្តើម

ឯកសារសង្ខេបនេះ នឹងផ្តល់ជាព័ត៌មានដល់សមាជិកព្រឹទ្ធសភាភូមិភាគ៥ ជាមូលដ្ឋានក្នុងការរៀបចំគម្រោងបេសកកម្មក្នុងខេត្តកែប និងកំពតនៅចុងខែ មីនា ឆ្នាំ២០១៦។ ឯកសារនេះនឹងបកស្រាយទៅលើសមត្ថភាព និងការអនុវត្តន៍ការងាររបស់ឃុំ/សង្កាត់ក្នុងខេត្តទាំងពីរនេះ។ ឯកសារនេះនឹងផ្តោតទៅលើបញ្ហាប្រឈម និងដំណោះស្រាយមួយចំនួនរបស់ក្រុមប្រឹក្សា ឃុំ សង្កាត់នៅក្នុងវិស័យសំខាន់ៗមួយចំនួន៖

១. ការអភិវឌ្ឍ ការអនុវត្ត និងតាមដានភាពជោគជ័យនៃផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់ដោយផ្តោតទៅលើការអភិវឌ្ឍប្រពន្ធ័ធារាសាស្រ្ត ផ្លូវថ្នល់ និងអគ្គិសនី

២. ការផ្តល់សេវាសាធារណៈទាក់ទងនឹងអគ្រានុកូលដ្ឋាន

៣. ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សង្គម

## ២. តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរ ៖ តួនាទីបំពីកិច្ចការមូលដ្ឋាន និងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។[1]

ពាក់ព័ន្ធនឹងកិច្ចការឃុំ សង្កាត់នៅមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមាន ប្រកបដោយចេរភាព សម្រាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួនដើម្បីបម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមគោលនយោបាយទូទៅរបស់រដ្ឋ។[2] ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋានរដ្ឋបាលឃុំ សង្កាត់មានភារកិច្ច ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឲ្យកិច្ចការទាំងនោះដំណើរការបានល្អ លើកទឹកចិត្តឲ្យមានការបង្កើនផាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ ជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌បេតិកភណ្ឌជាតិ សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឲ្យមានការយោគយល់អធ្យាស្រ័យគ្នាទៅវិញទៅមក និងបំពេញកិច្ចការទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[3]

ចំណែកឯតួនាទីជាភ្នាក់ងារតំណាងរដ្ឋវិញ ក្រុមប្រឹក្សាឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ករណីនេះ អាជ្ញាធរជួអាចធ្វើប្រតិភូកម្ម អំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវមធ្យោបាយបង្កើនសមត្ថភាព និងផ្តត់ផ្គង់សម្ភារៈ ថវិកា សម្រាប់អនុវត្ត។ ប្រតិភូកម្មខាងលើនេះត្រូវផ្តល់ចំពោះតែសមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។[4]

## ៣. ការវិភាជន៍ធនធាន ឃុំ សង្កាត់

ដើម្បីអនុវត្តការងាររបស់ក្រុមប្រឹក្សា ឃុំ សង្កាត់ ដោយគោរពតាមគោលនយោបាយវិមជ្ឈការ ការវិភាជន៍ ថវិកា និងធនធានមនុស្សគឺជាកត្តាសំខាន់សម្រាប់ដំណើរការនេះ។ មូលនិធិឃុំ សង្កាត់ត្រូវបានបង្កើត ឡើង ជាមូលនិធិដែលផ្ទេរពីរដ្ឋបាលថ្នាក់កណ្តាល សម្រាប់ការអភិវឌ្ឍនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។[5] មូលនិធិត្រូវបានចាត់ចែងសម្រាប់ការប្រើប្រាស់ក្នុងការងាររដ្ឋបាល និង ការអភិវឌ្ឍ។ ការប្រគល់ថវិកាទៅឲ្យឃុំ សង្កាត់ មានការកើនឡើងពី ១១៣,៣៤០ លានរៀល ទៅដល់ ៣០៨,៤១០ លានរៀល (២០០៩-២០១៦) ដូច្នេះ ជាមធ្យម ក្រុមប្រឹក្សានេះ អាចទទួលបានប្រមាណ ១៦៧លានរៀល រៀងរាល់ឆ្នាំ។[6] ប៉ុន្តែ របាយការណ៍របស់អង្គការ ខមហ្វ្រែល (COMFREL) បានបង្ហាញ ថា ថវិកានេះពុំគ្រប់គ្រាន់ឡើយ ដែលប្រហែលជាតម្រូវឲ្យមានការឧបត្ថម្ភមូលនិធិផ្សេងៗក្រៅពីរដ្ឋាភិបាល។[7]

កត្តាផ្សេងទៀតដែលប៉ះពាល់ដល់ការអនុវត្តការងាររបស់ឃុំ/សង្កាត់គឺ ធនធានមនុស្ស។ អំឡុងឆ្នាំ ២០០៧-២០១១ មន្ត្រីរាជការស៊ីវិលចំនួន ៧,៩៨៦នាក់ ត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធការងារ ឃុំ សង្កាត់។[8] ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមដែលសំខាន់ទាំង អស់ដែលឃុំ សង្កាត់កំពុងជួបប្រទះទាក់ទងនឹងធនធានមនុស្សគឺ ប្រវត្តិការសិក្សាមានកម្រិតទាប ដែលធ្វើ ឲ្យមានការរាំងស្ទះដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ យោងតាម លទ្ធផលការសម្ភាសន៍របស់អង្គការ ខមហ្វ្រែល (COMFREL) ៥៥ភាគរយ នៃក្រុមប្រឹក្សាឃុំ សង្កាត់ បានបញ្ចប់ការសិក្សាត្រឹមថ្នាក់ទី១ ដល់ទី៦។[9] ដោយមើលឃើញនូវកម្រិតយល់ដឹងរបស់ក្រុមប្រឹក្សា និង ដោយមានស្មៀនតែម្នាក់ស្ថិតក្នុងក្របខណ្ឌក្រសួងមហាផ្ទៃជាជំនួយការ ដូច្នេះការរៀបចំកម្មវិធីបណ្តុះ

បណ្តាលក្នុងកម្រិតជាក់លាក់មួយគួរត្រូវបានយកមកពិភាក្សាដើម្បីជួយឲ្យការងារឃុំ សង្កាត់ដែលមានអាណត្តិ ៥ឆ្នាំ កាន់តែមានប្រសិទ្ធិភាព។[10]

## ៤. ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅខេត្តកំពត និងកែប

ខេត្តកំពតមានស្រុកចំនួន១៨ ឃុំចំនួន៩២ និង ភូមិចំនួន៤៨២[11] ចំណែកខេត្តកែបវិញ មានតែស្រុកមួយ ក្រុងមួយ ឃុំពីរ សង្កាត់បី និងភូមិ៨ប៉ុណ្ណោះ[12]។ ស្រុកគឺជារដ្ឋបាលថ្នាក់ទីពីរនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបានចែកជាឃុំ និងបន្ទាប់មកជាភូមិ។ ចៅហ្វាយស្រុកទាំងអស់ត្រូវបានតែងតាំងឡើងដោយអភិបាលខេត្ត ប៉ុន្តែមេឃុំ ចៅសង្កាត់ និងក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយមានការចូលរួមពីគណបក្សនយោបាយជាច្រើនដើម្បីធានាឲ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមថ្នាក់មូលដ្ឋានប្រកបដោយចេរភាព។[13] ក្រុមប្រឹក្សាឃុំ សង្កាត់ បានសម្រេចការងារសំខាន់ៗជាច្រើនរួមមាន៖




**១. រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ៖** ប្រធានឃុំ សង្កាត់តម្រូវឲ្យធ្វើការយ៉ាងជិតស្និទ្ធជាមួយមេប៉ុស្តិ៍ឃុំ សង្កាត់ដើម្បីអនុវត្ត គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។ ក្នុងករណីនេះ មេប៉ុស្តិ៍ឃុំ សង្កាត់ត្រូវរាយការណ៍ជូនប្រធានគណៈបញ្ជាការឯកភាពស្រុក ខណ្ឌ ដើម្បីធានានូវសុវត្ថិភាពមូលដ្ឋានក្នុងដែនដីរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ដើរតួនាទីសំខាន់ក្នុងការដោះស្រាយទំនាស់នានាក្នុងមូលដ្ឋានរបស់ខ្លួនដែលរួមមាន៖ អំពើហិង្សាក្នុងគ្រួសារ ទំនាស់ព្រំដី[14] និងទំនាស់ដីធ្លី ដោយធ្វើការសម្របសម្រួលក្នុងការដោះស្រាយទំនាស់។[15] ក្រុមប្រឹក្សាឃុំ សង្កាត់នៅខេត្តទាំងពីរនេះមានភាពសកម្មក្នុងការធានាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងដែនដីដែលពួកគេ

គ្រប់គ្រង។ ភាពសកម្មក្នុងការងារនេះបាននាំឲ្យមានការថយចុះនៃចំនួនករណីបទសល្មើសព្រហ្មទណ្ឌ (ឃាតកម្ម ចោរប្លន់ ចាប់ជំរិត ចោរលួច និងបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត) ពី ៧៥៧ ករណី ទៅ ៦៣៦ ករណី នៅខេត្តកំពត។ ប៉ុន្តែ ខេត្តកែបហាក់ដូចជាទទួលបានលទ្ធផលផ្ទុយពីខេត្តកំពតក្នុងករណីបទល្មើសព្រហ្មទណ្ឌដោយមានការកើនឡើងពី១ករណី រហូតដល់១៨ករណី(ពីឆ្នាំ២០១២ ទៅឆ្នាំ២០១៤)។ ទិន្នន័យនេះបង្ហាញថាក្រុមប្រឹក្សាឃុំ សង្កាត់បានប្តេជ្ញាចិត្តដើម្បីអនុវត្តនូវគោលនយោបាយ ភូមិ ឃុំមានសុវត្ថិភាពក្នុងការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ និងអំពើហិង្សា (សូមមើលក្នុងផែនទីខាងលើ)។ តួលេខពីករណីបទល្មើសព្រហ្មទណ្ឌនៅខេត្តទាំងពីរនេះមានការផ្លាស់ប្តូរ ក៏បញ្ជាក់ផងដែរថាកិច្ចសហការរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងនគរបាលមានការប្រសើរឡើងផងដែរ។

**២. ធ្វើឲ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធថ្នាក់មូលដ្ឋានតាមរយៈផែនការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន៖** យោងទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ រាជរដ្ឋាភិបាលគ្រោងនឹងអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ័នៅតាមតំបន់ជនបទ ជាពិសេស ផ្លូវលំ ភ្លើងអគ្គិសនី និងការទទួលបានទឹកស្អាតសម្រាប់បរិភោគ។ ផែនការបញ្ជាក់ថានៅចុងឆ្នាំ២០១៨ នឹងមានការសាងសង់ផ្លូវរហូតដល់ ២,៣៣០គីឡូម៉ែត្រ នៅក្នុងឆ្នាំនេះ (២០១៦) ប្រជាជននៅជនបទ ៥៣ភាគរយ អាចទទួលបានទឹកស្អាតសម្រាប់បរិភោគ ហើយភាគរយនេះនឹងកើនឡើងដល់៦០ភាគរយ នៅចុងឆ្នាំ២០១៨។ ជាងនេះទៅទៀត សម្រាប់ភ្លើងអគ្គិសនីរាជរដ្ឋាភិបាលក៏មានគម្រោងបង្កើតឲ្យបាន ៧.៥១៦ លានគីឡូវ៉ាត់ នៅចុងឆ្នាំ២០១៦ និង ពង្រីកបរិមាណដល់ ៩.០១៩ និង១០.៨២៣លានគីឡូវ៉ាត់ នៅចុងឆ្នាំ២០១៧ និងឆ្នាំ២០១៨។[16] លើសពីនេះទៅទៀត នៅឆ្នាំនេះ(២០១៦) ប្រជាជនចំនួន ៥៣ភាគរយនឹងទទួលបានទឹកស្អាតបរិភោគ ហើយភាគរយនឹងកើនឡើងដល់៦០ភាគរយនៅចុងឆ្នាំ២០១៨។

ជាងនេះទៅទៀត ទិន្នន័យក៏បានបង្ហាញថាចំនួនគ្រួសារដែលទទួលបានទឹកស្អាតប្រើប្រាស់មានការកើនឡើងគួឲ្យកត់សម្គាល់នៅខេត្តកែប និងកំពត ដោយសារតែផែនការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋានសម្រាប់ធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាព និងគុណភាពនៃការរស់នៅ ក៏ដូចជាធ្វើឲ្យប្រសើរឡើងនូវអនាម័យ និងការអនុវត្តន៍ភាពស្អាត។ *សូមមើលក្រាហ្វិចទី១ ខាងក្រោម៖*

### ក្រាហ្វិចទី១៖ ប្រភេទទឹកប្រើប្រាស់នៅខេត្តកំពត និងកែប ក្នុង១០០០គ្រួសារ




ប្រភព៖ ទិន្នន័យមូលដ្ឋានឃុំ មន្ទីរផែនការខេត្ត

ឃុំ សង្កាត់នីមួយៗមានគម្រោងវិនិយោគនៅក្នុងសហគមន៍របស់ពួកគេដើម្បីធ្វើឲ្យប្រសើរឡើងនូវការអភិវឌ្ឍមូលដ្ឋានតាមរយៈមូលនិធិឃុំ សង្កាត់[17] ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងខេត្តទាំងពីរនេះ ក៏បានអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ជនបទ ដើម្បីធានាការអភិវឌ្ឍសហគមន៍របស់ពួកគេ រួមមាន ជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ធ្វើឲ្យប្រសើរឡើងនូវប្រពន្ធ័ធារាសាស្ត្រ ផ្គត់ផ្គង់ទឹកស្អាតនៅតាមតំបន់ជនបទ និងទទួលទឹកស្អាតប្រើប្រាស់។ គម្រោងទាំងនេះ តែងតែឆ្លុះបញ្ចាំងពីគម្រោងអភិវឌ្ឍន៍ឃុំ និងគម្រោងវិនិយោគឃុំ។ មិនមានទិន្នន័យផ្លូវការណាមួយពីខេត្តទាំងពីរនេះមកធ្វើការវិភាគបានទេ។ ទោះបីជាយ៉ាងណាក៏ដោយ គម្រោងអភិវឌ្ឍន៍របស់ឃុំ សង្កាត់ មានចំនួន១,៨០០គម្រោង ក្នុងនោះ៨០ភាគរយ សម្រាប់ផ្លូវជនបទ ៧,៣ ភាគរយ សម្រាប់ប្រព័ន្ធធារាសាស្ត្រ ៥ភាគរយ សម្រាប់ផ្លូវទីប្រជុំជន និងគម្រោងផ្សេងៗទៀត (សូមមើលតារាងទី១)។[18] ជាងនេះទៅទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលលើការផ្តល់សេវាសាធារណៈតាមរយៈការអនុវត្ត និងត្រួតពិនិត្យឡើងវិញលើគម្រោងអភិវឌ្ឍន៍ឃុំ គម្រោងវិនិយោគឃុំ ដែលបានអនុវត្តដោយការដេញថ្លៃ ឬក៏ស្ថិតនៅក្រោមការគាំទ្របច្ចេកទេសពីបណ្តាញក្រសួងជំនាញ ឬក៏មន្ទីរជំនាញ។[19]

ទោះបីជាការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងខេត្តទាំងពីរនេះ បានធ្វើឲ្យប្រសើរឡើង ប៉ុន្តែបញ្ហាប្រឈមរបស់ឃុំ សង្កាត់នៅតែមាននៅឡើយ។ ឧទាហរណ៍ ហិរញ្ញវត្ថុសម្រាប់ថៃទាំប្រពន្ធ័ធារាសាស្ត្រ ជួសជុល និងកសាងមានការកើនឡើងយឺតដែលមិនអាចឆ្លើយតបនឹងតម្រូវការជាក់ស្តែងបាន។[20] ជាងនេះទៅទៀត ការបែងចែកថាមពលអគ្គិសនី ការពង្រីកបណ្តាញចែកចាយទៅតាមតំបន់ជនបទនៅមានកម្រិតនៅឡើយ ហើយថាមពលអគ្គិសនីដែលបានមកពីរោងចក្រវារីអគ្គិសនីអាចផ្គត់ផ្គង់គ្រប់គ្រាន់នៅតែរដូវវស្សាប៉ុណ្ណោះ ប៉ុន្តែនៅរដូវផ្សេងទៀត ថាមពលអគ្គិសនីបានបន្ថយរហូតដល់ទៅ ២៥ភាគរយ។[21]

ទាក់ទងនឹងតម្លាភាព អនុក្រឹត្យស្តីពី ការគ្រប់គ្រងប្រពន្ធ័ហិរញ្ញវត្ថុរបស់ឃុំ សង្កាត់បានបញ្ជាក់ថា ហេដ្ឋា-រចនាសម្ព័ន្ធ ឬក៏គម្រោងអភិវឌ្ឍន៍ដែលអនុវត្តដោយឃុំ សង្កាត់ត្រូវតែដាក់ដេញថ្លៃជាសាធារណៈ។[22] ដើម្បីបង្កើនអំណាចដល់ឃុំ សង្កាត់ និងធានាថាសេវា និងការងារដែលបានធ្វើទាំងអស់ប្រកបដោយតម្លាភាព និងគណនេយ្យភាពដោយមិនចាំបាច់ពឹងផ្អែកទៅលើថ្នាក់រដ្ឋបាលផ្សេងទៀតក្នុងការផ្តល់សេវាទាំងនេះ ដំណើរការនៃការដេញថ្លៃត្រូវបានបង្កើតឡើង។[23] ជាទូទៅក្នុងដំណើរការដេញថ្លៃ មានប្រាំមួយជំហ៊ានដូចជា៖

១. កិច្ចប្រជុំផ្សព្វផ្សាយការដេញថ្លៃរយៈពេលពីរសប្តាហ៍នៅក្រុមប្រឹក្សាឃុំ

២. កិច្ចប្រជុំ និងសកម្មភាពដេញថ្លៃដូចខាងក្រោម៖

- កិច្ចប្រជុំណែនាំពីការដេញថ្លៃ
- ការដាក់ដេញថ្លៃយ៉ាងហោចណាស់ ៣០នាទីបន្ទាប់ពីការណែនាំពីការដេញថ្លៃបានបញ្ចប់
- បើកការដេញថ្លៃ
- វាយតម្លៃការដេញថ្លៃ (ដោយ គណៈកម្មាធិការលទ្ធកម្មហើយមិនមានវត្តមានអ្នកដេញថ្លៃទេ)

៣. ប្រកាសលទ្ធលបង្ហាញឈ្មោះអ្នកដែលដេញថ្លៃបាន

៤. មន្ត្រីជំនួយបច្ចេកទេសរាយការណ៍ទៅអភិបាលខេត្តថាដំណើរការដេញថ្លៃបានធ្វើតាមការណែនាំ

៥.អនុម័តលើផែនការ

៦.ចុះកិច្ចសន្យានៅក្រោយពេលប្រកាសពីការវាយតម្លៃរយៈពេលមួយសប្តាហ៍។[24]

**តារាង ១៖ ប្រភេទគម្រោងដែលវិនិយោគដោយឃុំ សង្កាត់ ២០០៩-២០១៥**

| ប្រភេទគម្រោង | ហ្វ្រេកង់ | ភាគរយ |
|---|---|---|
| ផ្លូវជនបទ | ២៣.៣៦៦ | ៨២,៦៩ |
| ប្រព័ន្ធធារាសាស្ត្រ | ២.០៦០ | ៧,២៩ |
| ផ្លូវទីប្រជុំជន | ១.៤៥៦ | ៥,១៣ |
| កសិកម្ម | ៤៤៩ | ១,៥៩ |
| ផ្គត់ផ្គង់ទឹកស្អាតនៅតាមតំបន់ជនបទ | ២៩០ | ១,០៣ |
| ប្រព័ន្ធបង្ហូរទឹក និងការពារទឹកជំនន់នៅទីប្រជុំជន | ១៤៣ | ០,៥១ |
| អប់រំ | ១០១ | ០,៣៦ |
| ប្រព័ន្ធបង្ហូរទឹក និងការពារទឹកជំនន់នៅជនបទ | ៩៤ | ០,៣៣ |
| សហគមន៍នេសាទ | ៨៥ | ០,៣ |
| សហគមន៍ព្រៃឈើ | ៧៨ | ០,២៨ |
| ការគ្រប់គ្រងបរិស្ថាន | ៤៩ | ០,១៧ |
| អនាម័យ | ៣០ | ០,១១ |
| ការអភិវឌ្ឍន៍ទេសចរណ៍ | ៣០ | ០,១១ |
| អគ្គីសនី | ៩ | ០,០៣ |
| សំរាម | ៥ | ០,០២ |
| ការគ្រប់គ្រងធនធានទឹកសហគមន៍ | ៤ | ០,០១ |
| សុខាភិបាល | ៤ | ០,០១ |
| ហេដ្ឋារចនាសម្ព័ន្ធផ្សារ | ៤ | ០,០១ |
| ការអន្តរាគមន៍ផ្នែកសង្គម | ៣ | ០,០១ |
| ការផ្គត់ផ្គង់ទឹកនៅតាមទីប្រជុំជន | ៣ | ០,០១ |

ប្រភព៖ ទិន្នន័យនៃការអនុវត្តន៍គម្រោង របស់គ.ជ.អ.ប

៣. **ការផ្តល់សេវាសាធារណៈទូទៅ៖** យោងលើផែនការយុទ្ធសាស្ត្រ រដ្ឋាភិបាលបានសង្កត់ធ្ងន់លើការកែលម្អសេវាសាធារណៈនៅតំបន់ជនបទតាមរយៈការពង្រឹងគុណភាព និងការចែកចាយសេវាសាធារណៈ

បូករួមទាំងការកែលម្អការគ្រប់គ្រងធនធានមនុស្ស។ ដើម្បីធ្វើឲ្យសេវាសាធារណៈមានភាពប្រសើរឡើង គុណភាព និងការផ្តល់សេវាសាធារណៈ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង(ICT) និងយន្តការដែលអាចជួយធ្វើឲ្យប្រសើរឡើងដល់ការផ្តល់សេវាសាធារណៈទៅកាន់តំបន់ដាច់ស្រយាល ត្រូវបានលើកកម្ពស់ ។[25] ទោះជាយ៉ាងណាក៏ដោយ មានតែ ទិន្នន័យអំពីការចុះអត្រានុកូលដ្ឋានតែមួយគត់នៃការផ្តល់សេវាសាធារណៈទូទៅ ដែលអាចកំណត់នូវសកម្មភាពរបស់ឃុំ សង្កាត់បាន។ ក្រុមប្រឹក្សាឃុំ សង្កាត់គឺមានតួនាទីយ៉ាងសកម្មក្នុងការជូនដាដំណឹង និងលើកទឹកចិត្តប្រជាជនក្នុងការទទួលយកនូវសេវាចុះបញ្ជីអត្រានុកូលដ្ឋាន(Civil registration)ទាំងនេះ រួមមានការចុះបញ្ជីអត្រានុកូលដ្ឋាន អត្តសញ្ញាណ-ប័ណ្ណ សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅ ដែលការចុះបញ្ជីទាំងនេះជាការទទួលខុសត្រូវរបស់ប៉ូលិស។ ការធ្វើការងាររបស់ពួកគាត់ក្នុងការផ្តល់សំបុត្រកំណើត និង ការផ្តល់ឯកសារផ្សេងៗទៀត ព្រមទាំងការចុះសំបុត្រអាពាហ៍ពិពាហ៍ត្រូវបានគេទទួលស្គាល់យ៉ាងខ្លាំង។

នៅក្នុងឆ្នាំ២០១២ ឃុំ សង្កាត់ភាគច្រើន ចាប់ផ្តើមយកចិត្តទុកដាក់បន្ថែមទៀតលើការផ្តល់សេវាសង្គម ដោយការបែងចែកមូលនិធិឃុំ សង្កាត់របស់ពួកគាត់ សម្រាប់គាំទ្រវាល់សកម្មភាព បូករួមទាំងការចុះសំបុត្រកំណើត បើធៀបនឹងឆ្នាំ ២០១១ ដែលមូលនិធិឃុំ សង្កាត់ភាគច្រើនត្រូវបានចំណាយតែលើហេដ្ឋា-រចនាសម្ព័ន្ធ។[26] អត្រានៃការចុះសំបុត្រកំណើតនៅក្នុងខេត្តកំពត និងខេត្តកែប ក៏បានកើនឡើងចាប់តាំងពីឆ្នាំ ២០១២មកផងដែរ។ ភាគរយនៃកុមារ(៣០ថ្ងៃបន្ទាប់ពីប្រសូត្រ)ដែលបានចុះសំបុត្រកំណើតបានកើនឡើងចាប់ពី ៦៥,៥% ទៅ ៧៧,៧% នៅក្នុងខេត្តកំពត[27] និងកើនឡើងពី៦៧,៣% ទៅ៨៦,៧% នៅក្នុងខេត្តកែប [28] (២០១២-២០១៤)។ ទោះជាយ៉ាងណាក៏ដោយ នៅតែមានបញ្ហាប្រឈមក្នុងការផ្តល់សេវាសាធារណៈទូទៅ នៅឃុំ សង្កាត់ ។ ជាឧទាហរណ៍ដូចជា ឪពុកម្តាយបានយល់ឃើញថាដំណើរការនៃការចុះសំបុត្រកំណើតនេះគឺមានលក្ខណៈស្មុគ្រស្មាញ ជាពិសេសនៅក្នុងករណីដែលទៅចុះឈ្មោះយឺតយ៉ាវ។ លើសពីនេះទៅទៀត ការគ្រប់គ្រងទិន្នន័យគឺនៅពុំទាន់មានគុណភាពខ្ពស់ ដោយហេតុថា ទិន្នន័យនៅលើក្រដាស និងប្រព័ន្ធត្រួតពិនិត្យទិន្នន័យដោយដៃបានធ្វើឲ្យគុណភាពនៃព័ត៌មាននៅមានកម្រិត ឬលំហូរនៃព័ត៌មានមិនទៀងទាត់។[29] ទោះបីជា រដ្ឋាភិបាលមានផែនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ( ICT) ដូចដែលការលើកឡើងខាងលើក៏ដោយ សមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាលដែលនៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងបច្ចេកវិទ្យាទំនើប គឺជាឧបសគ្គមួយដែលត្រូវឆ្លងកាត់ដើម្បីសម្រេចឲ្យបានជោគជ័យ។[30]

បន្ថែមពីលើបញ្ហាប្រឈមក្នុងការផ្តល់សេវាសាធារណៈ ឃុំ សង្កាត់ក៏កំពុងជួបការលំបាកផងដែរជាមួយនឹងបញ្ហាដ៏ទៃទៀតនៅក្នុងសហគមន៍របស់ពួកគាត់ ដូចជាបញ្ហាការធ្វើចំណាកស្រុកជាដើម។ នៅក្នុងខេត្តទាំងពីរនេះ ប្រជាជនមានបំណងធ្វើចំណាកស្រុកទៅកាន់ប្រទេសដ៏ទៃទៀត ឬក៏ខេត្តដ៏ទៃទៀត ដើម្បីស្វែងរកឱកាសការងារដ៏ល្អប្រសើរមួយ។ ជាលទ្ធផល នៅក្នុងខេត្តកំពត ភាគរយប្រជាជនដែលមានអាយុ ១៨ ឆ្នាំ និងលើស១៨ឆ្នាំ ធ្វើការចំណាកស្រុកទៅកាន់កន្លែងដ៏ទៃទៀតដើម្បីស្វែងរកការងារនៅក្នុងប្រទេសបានកើនឡើងចាប់ពី ៨,៥% ក្នុងឆ្នាំ ២០១២ ទៅ ១០,៩% ក្នុងឆ្នាំ ២០១៤ និងទៅកាន់ប្រទេសដ៏ទៃទៀតកើនឡើងចាប់ពី ៣,៥% ទៅ៥%។[31] នៅក្នុងខេត្តកែប ភាគរយនៃអ្នកចំណាកស្រុកនៅក្នុងប្រទេសកើនឡើងពី ៦,៧% ទៅ ៩,៩% និងចំណាកស្រុកទៅក្រៅប្រទេសកើនឡើងពី ១,៨% ទៅ២,៥% ចន្លោះឆ្នាំ ២០១២ និង ២០១៤។[32]

## ៥.សេចក្តីសន្និដ្ឋាន

ការអនុវត្តការងារក្រុមប្រឹក្សាឃុំ សង្កាត់របស់ ខេត្តកែប និងកំពតមានការរីកចម្រើន។ ទោះបីថវិកានិងធនធានមនុស្សនៅមានកម្រិត ក្រុមប្រឹក្សា ឃុំសង្កាត់នៅតែជារដ្ឋបាលថ្នាក់ក្រោមជាតិដ៏សំខាន់ក្នុងការធានាការអភិវឌ្ឍសេដ្ឋកិច្ច សង្គម របស់ខេត្តទាំងពីរនេះ។ ក្រុមប្រឹក្សានេះ មានតួនាទីដ៏សំខាន់ក្នុងការសម្របសម្រួល និងជំរុញឲ្យការងារផ្តល់សេវាសាធារណៈកាន់តែមានប្រសិទ្ធិភាពក្នុងមូលដ្ឋានពួកគេ។ ក្នុងបរិបទការអនុវត្ត វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមប្រឹក្សា ឃុំសង្កាត់អនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដោយការព្យាយាមពង្រឹង និងធ្វើសហប្រតិបត្តិការល្អជាមួយប៉ុស្តិ៍ប៉ូលិស ដើម្បីធានាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សង្គមក្នុងមូលដ្ឋានរបស់ពួកគេ។ ទោះយ៉ាងនេះក្តី ជោគជ័យក្នុងការអនុ-វត្ត មូលដ្ឋានគម្រោងអភិវឌ្ឍន៍ឃុំ និងគម្រោងវិនិយោគឃុំទាមទារឲ្យមានពេលវេលា និងថវិកាគ្រប់គ្រាន់ដែលផ្តល់ដោយក្រសួង និងនាយកដ្ឋានជំនាញបច្ចេកទេស។ ក្រៅពីការចុះសំបុត្រកំណើត លិខិតអាពាហ៍ពិពាហ៍ និងការងាររដ្ឋបាលមូលដ្ឋានផ្សេងទៀត សមិទ្ធិផលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈគឺស្របនឹងគោលដៅអាទិភាពរបស់រដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងន័យនេះ អាចបញ្ជាក់បានថា ក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខេត្តទាំងពីរបានដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលឲ្យមានការអភិវឌ្ឍក្នុងតំបន់ពួកគេ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ មូលនិធិឃុំ និងសង្កាត់គិតជាលានរៀល

| ឆ្នាំ | ផ្នែករដ្ឋបាល | ផ្នែកការអភិវឌ្ឍន៍ | សរុប | ផលធៀបទៅនឹងចំណូលចរន្តរបស់ជាតិ |
|---|---|---|---|---|
| 2009 | 34,324.10 | 79,015.90 | 113,340.00 | 2.75% |
| 2010 | 38,648.74 | 110,000.26 | 148,649.00 | 2.80% |
| 2011 | 52,602.00 | 106,798.00 | 159,400.00 | 2.80% |
| 2012 | 52,737.00 | 129,253.00 | 181,990.00 | 2.80% |
| 2013 | 54,107.00 | 150,311.00 | 204,418.00 | 2.80% |
| 2014 | 105,230.00 | 132,036.00 | 237,266.00 | 2.80% |
| 2015 | 139,795.00 | 132,159.00 | 271,954.00 | 2.80% |
| 2016 | 185,119.24 | 123,290.76 | 308,410.00 | 2.80% |
| **សរុប** | **825,840.80** | **1,266,182.64** | **2,092,023.44** | |

ប្រភព: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# ឧបសម្ព័ន្ធ២៖  ករណីបទល្មើសតាមឃុំ នៅខេត្តកំពត និងកែប



## ឧបសម្ព័ន្ធ៣៖ ដំណើរការដេញថ្លៃ



# ឯកសារយោង

[1] 2001 Law on Administrative Management of the Commune/Sangkat Cambodia.
[2] Ibid.
[3] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឆ្នាំ២០០១ មាត្រា ៤៣
[4] ដូចខាងលើ មាត្រា៤៤
[5]According to the law on commune/sangkat administrative management 2001, the budgets of the commune and sangkat come from two main sources: the budget from the annual state budget; and their own financial resources from fiscal and non-fiscal taxes, other service charges, etc. (Articles 74 and 78).
[6] Actual commune/Sangkat fund resources in 2009 to 2016 are reflected in the annex 1.
[7] COMFREL 2013. Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007-2012. Phnom Penh COMFREL.p.17.
[8] NCDD 2012. Report on the Achievement of Implementation of Commune/Sangkat Council in the 2nd Legislature 2007-2011. Phnom Penh, Cambodia: NCDD ,p.27.
[9] COMFREL 2013. Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007-2012. Phnom Penh COMFREL.P.20.
[10] CHHEAT, S. 2014 Impact of Decentralization on Cambodian's Urban Governance. *CDRI Working Paper* ,p.88.
[11] NATIONAL INSTITUTE OF STATISTICS & MINISTRY OF PLANNING 2013. *Economic Census of Cambodia 2011: Provincial Report, 07 Kampot Province,* Phnom Penh, Cambodia National Institute of Statistics,.
[12] NATIONAL INSTITUTE OF STATISTICS & MINISTRY OF PLANNING 2013 *Economic Census of Cambodia 2011 Provincial Report Kep Province.,* Phnom Penh, Cambodia National Institute of Statistics, .
[13] NAGOYA UNIVERSITY 2007. Overseas fieldwork Report 2006: Kampot Province, Cambodia. Phnom Penh, Cambodia: Nagoya University, .
[14] WORLD BANK & ASIA FOUNDATION 2012. Voice, Choice and Decision: A Study of Local Governance Processes in Cambodia. Phnom Penh, Cambodia The Asia Foundation ,p.19.
[15] COMFREL 2013. Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007-2012. Phnom Penh COMFREL.p.15.
[16] ROYAL GOVERNMENT OF CAMBODIA 2014 National Strategic Development Plan 2014-2018 : For Growth,Employment, Equity and Efficiency to Reach Upper Middle Income Country Phnom Penh, Cambodia: Royal Government of Cambodia, . p. viii.
[17] 2.8% of Recurrent Revenue of the National Budget,UNICEF 2013 -b. Cambodia issue brief: Strengthening sub-national planning and budgeting to improve service delivery and child development. Phnom Penh, Cambodia: UNICEF.
[18] NCDD 2012. Report on the Achievement of Implementation of Commune/Sangkat Council in the 2nd Legislature 2007-2011. Phnom Penh, Cambodia: NCDD
[19] CHEA, S. M., CHHAN, P., HTAY, W. M. M., KEM, K., NHIEP, S. & THENG, N. 2016 Enhancing Local Development of Sangkat in Phnom Penh. Phnom Penh, Cambodia: Parliamentary Institute of Cambodia, .
[20] ROYAL GOVERNMENT OF CAMBODIA 2014 National Strategic Development Plan 2014-2018 : For Growth,Employment, Equity and Efficiency to Reach Upper Middle Income Country Phnom Penh, Cambodia: Royal Government of Cambodia, .p.45.
[21] Ibid.p.47.
[22] NATIONAL COMMITTEE TO SUPPORT THE COMMUNES 2002 Sub-Decree Commune/Sangkat Financial Management System. Phom Penh National Committee to Support the Communes,. Article 46.
[23]COMFREL 2013. Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007-2012. Phnom Penh COMFREL. p.12
[24] SHRESTHA, P. M. 2005. Copyright© International Labour Organization 2005 First published 2005.p.38.
[25] Ibid.pp.110-111.
[26] COMFREL 2013. Assessment of the Second Term of Decentralization in Cambodia: Commune Council Performance and Citizens' Participation, 2007-2012. Phnom Penh COMFREL. p.25.
[27] PROVINCIAL DEPARTMENT OF PLANNING 2015 *Profile On Economic and Social in Year 2015, Kampot province,* Phnom Penh, Cambodia Provincial Department of Planning, .p.53.
[28] PROVINCAL DEPARTMENT OF PLANNING 2015 *Profile On Economic and Social in Year 2015, Kep province,* Phnom Penh, Cambodia, Provincial Department of Planning, .p.55.
[29] UNICEF 2013 -a. Cambodia Issue Brief on Birth Registration: For every child the fundamental right to an identity. Phnom Penh, Cambodia UNICEF

[30] ROYAL GOVERNMENT OF CAMBODIA 2014 National Strategic Development Plan 2014-2018 : For Growth,Employment, Equity and Efficiency to Reach Upper Middle Income Country Phnom Penh, Cambodia: Royal Government of Cambodia, .p.49.
[31] PROVINCIAL DEPARTMENT OF PLANNING 2015 *Profile On Economic and Social in Year 2015, Kampot province,* Phnom Penh, Cambodia Provincial Department of Planning, .p.22.
[32] PROVINCAL DEPARTMENT OF PLANNING 2015 *Profile On Economic and Social in Year 2015, Kep province,* Phnom Penh, Cambodia, Provincial Department of Planning, .p.20.